**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :**......០១៥/១៨......**ក.ប**/ស.ជ.ណ.គ.ក.ប

## សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១៣២ ទិវាពលកម្មអន្តរជាតិ
## ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងអំពីការរៀបចំ **ប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣២ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨** ដូចតទៅៈ

១-ការរៀបចំប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី ១៣២ ទិវាពលកម្មអន្តរជាតិ ១ឧសភា ក្រោមប្រធានបទ "**សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ**"។

២-គ្រប់ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំចាត់តាំងពិធីជួបជុំសំណេះសំណាល អបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា នៅតាមមូលដ្ឋានរៀងៗខ្លួន និងសហការជាមួយសហគ្រាស គ្រឹះស្ថាន អង្គការសហជីព ដើម្បីផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាល សារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣-ត្រូវចងបដាពាក្យស្លោកនៅតាមដងផ្លូវសាធារណៈ ក្រសួង ស្ថាប័ន និងសហគ្រាស គ្រឹះស្ថាន នូវពាក្យស្លោកដូចខាងក្រោមៈ

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ
- គោរពច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីសហជីព ដើម្បីជានាសិទ្ធិ និងផលប្រយោជន៍រួមរបស់កម្មករនិយោជិត និងនិយោជក
- ចូលរួមយុទ្ធនាការគ្រោះថ្នាក់ការងារកម្រិតសូន្យ
- អភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីសុខុមាលភាពកម្មករនិយោជិត
- អភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីផលិតភាព និងភាពប្រកួតប្រជែង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩